# IWITNESS

## Testimonies by Survivors of the Khmer Rouge

## សក្ខីកម្មរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

# STEPS TO HEAL:

## TPO'S WORK WITH TESTIMONY

The Transcultural Psychosocial Organization (TPO) is the leading Cambodian non-governmental organization in the field of mental health and psychosocial interventions. Since its foundation in 1994, TPO's goal is to promote psychological healing for those who suffered under the Khmer Rouge genocide and the war thereafter.

Tens of thousands of people were murdered and tortured to death as the Khmer Rouge leaders imposed radical social transformations onto Cambodian traditional society, brutally challenging the way people made sense of their own existence, their relationships to others, and to the spiritual world. Today, Cambodians continue to carry the burden of having lived through this harrowing history, yet as testament to their resilience, courage and tenacity the Cambodian social fabric is healing and the people continue to strive, despite high levels of psychological and social trauma.

The Extraordinary Chambers in the Courts of Cambodia (ECCC) are the first serious effort to prosecute the senior leaders of the Khmer Rouge. The first trial against Kaing Guek Eav, known as "Duch", head of the notorious Tuol Sleng prison, ended in November 2009. On July 26, 2010 Duch was sentenced to 35 years imprisonment. The court reduced the sentence to 19 years on the grounds that he had been detained illegally for years before the tribunal was established.

Cambodians have said they want justice and accountability for human rights crimes committed during the Khmer Rouge era. However, the emotional and psychological impact of the tribunal on the wellbeing of survivors is still in question. TPO wants to address the psychological needs by linking the national symbolic process of the ECCC with the opportunity for survivors to reflect on their past and to speak about their own experiences. By providing a space for memory in which individuals can reconstitute their identities by reflecting on the past in a highly personalized way, TPO hopes to promote healing in the wake of trauma.

The extracts and images presented here are from interviews conducted in August and September 2010. The intent is to give Khmer Rouge survivors a voice and to break the enforced silence about their suffering and continuous struggle in coming to terms with their past. The views expressed here are from each individual and do not necessarily reflect the opinions of TPO.

We would like to thank Zélie Pollon and Alan M. Thornton for their wholehearted commitment to this book project, and for their sensitive understanding of those who shared their experiences in the process.

DR CHHIM SOTHEARA, EXECUTIVE DIRECTOR, TPO

# ជំហានឆ្ពោះទៅរកការជាសះស្បើយ ៖

## ការងារសក្ខីកម្មរបស់អង្គការ TPO

អង្គការចិត្តសង្គមអន្តរវប្បធម៌ (ធី ភី អូ) ជាអង្គការមិនមែនរដ្ឋាភិបាលមួយនៅកម្ពុជា ដែលធ្វើការឈានមុខក្នុងវិស័យសុខភាពផ្លូវចិត្ត និង ផ្តល់អន្តរាគមលើបញ្ហាចិត្តសង្គម។ ចាប់តាំងពីបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៤ ធីភីអូ មានគោលដៅលើកកម្ពស់ការព្យាបាលផ្លូវចិត្តដល់ប្រជាជនកម្ពុជា ដែលរងគ្រោះក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម និងសង្គ្រាមបន្តបន្ទាប់។

ក្រៅតែពីការកាប់សម្លាប់ និង ធ្វើទារុណកម្មលើប្រជាជនរាប់ម៉ឺននាក់ មេដឹកនាំខ្មែរក្រហមបានបង្ខំឲ្យសង្គមផ្លាស់ប្តូរដល់ឫសគល់ រួមមាន លើផ្នែកប្រពៃណីខ្មែរ ការប្រឆាំងទៅនឹងជំនឿរបស់ខ្លួន ទាំងលើផ្នែកទំនាក់ទំនងជាមួយអ្នកដទៃនិងជាមួយពិភពព្រលឹងវិញ្ញាណរបស់ខ្លួន។ បច្ចុប្បន្ននេះ ប្រជាជនកម្ពុជាកំពុងបន្តរងបន្ទុកនៃជីវិតដែលបានឆ្លងកាត់រឿងរ៉ាវឈឺចាប់ទាំងនេះ ប៉ុន្តែដោយសារភាពរឹងមាំ សេចក្តីក្លាហាននិងការតស៊ូរបស់ខ្លួន សង្គមកម្ពុជាកំពុងជួសជុលរចនាសម្ព័ន្ធឡើងវិញ រីឯប្រជាជនកម្ពុជាកំពុងបន្តប្រឹងប្រែងសូម្បីការប៉ះទង្គិចផ្លូវចិត្តនិងសង្គមនៅមានកំរិតខ្ពស់ក៏ដោយ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ៊ីស៊ីស៊ីស៊ី) ជាស្ថាប័នដំបូងគេបង្អស់ ដែលខិតខំប្រឹងប្រែងកាត់ទោសមេដឹកនាំខ្មែរក្រហមកំពូលៗ។ ការជំនុំជម្រះលើកទីមួយប្រឆាំងនឹង កាំង ហ្គេកអ៊ាវ ហៅឌុច អតីតប្រធានគុកទួលស្លែង បានបញ្ចប់ក្នុងខែវិច្ឆិកា ឆ្នាំ២០០៩។ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឌុចត្រូវគេកាត់ទោសឲ្យ ជាប់ពន្ធនាគារចំនួន៣៥ឆ្នាំ។ តុលាការនេះបានបន្ថយទោសមកនៅត្រឹមតែ១៩ឆ្នាំដោយមូលហេតុថា គេបានឃុំឃាំងគាត់ដោយខុសច្បាប់អស់រយៈពេលជាច្រើនឆ្នាំមុនពេលបង្កើតតុលាការនេះ។

ប្រជាជនកម្ពុជាបាននិយាយថា ពួកគេចង់បានយុត្តិធម៌ និង ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងសិទ្ធិមនុស្ស ដែលបានប្រព្រឹត្តក្នុងសម័យខ្មែរក្រហម។ ប៉ុន្តែផលប៉ះពាល់ផ្នែកផ្លូវចិត្ត និង អារម្មណ៍នៃការជំនុំជម្រះក្តីនេះ មកលើសុខុមាលភាពរបស់ជនរងគ្រោះនៅតែជាបញ្ហានៅឡើយ។ ឧទាហរណ៍ មានប្រជាជនជាច្រើននាក់មិនបានពេញចិត្តចំពោះការកាត់ក្តីនិងការដាក់ទោសចំពោះ ឌុច ឡើយ ដែលនេះធ្វើឲ្យការចងចាំអំពីអំពើហិង្សា និងភាពអយុត្តិធម៌ ដែលកប់យ៉ាងជ្រៅក្នុងចិត្តរបស់ពួកគាត់បានផុសចេញឡើងមកជាថ្មី។ ធីភីអូ យកចិត្តទុកដាក់លើតម្រូវការផ្នែកផ្លូវចិត្តទាំងនោះ ដោយផ្សារភ្ជាប់ដំណើរការជានិមិត្តរូបជាតិ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទៅនឹងឱកាសឲ្យជនរងគ្រោះបានឆ្លុះបញ្ចាំងអំពីរឿងអតីតកាលរបស់ពួកគាត់ព្រមទាំងនិយាយអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគាត់។ តាមរយៈការផ្តល់លំហសម្រាប់ការចងចាំមួយ ដែលក្នុងនោះជនរងគ្រោះទាំងឡាយអាចបង្កើតឡើងវិញនូវអត្តសញ្ញាណរបស់ខ្លួនដោយឆ្លុះបញ្ចាំង អំពីអតីតកាលតាមសមត្ថភាពពិសេសផ្ទាល់ខ្លួនម្នាក់ៗនោះ ធីភីអូ សង្ឃឹមថានឹងជួយលើកកម្ពស់ការព្យាបាលការប៉ះទង្គិចផ្លូវចិត្តនេះបាន។

អត្ថបទដកស្រង់ និងរូបភាពនានាបង្ហាញនៅក្នុងសៀវភៅនេះ គឺបានមកពីបទសម្ភាសន៍ ដែលបានរៀបចំកាលពីខែកក្កដា និងខែកញ្ញា ឆ្នាំ២០១០។ គោលបំណងនោះ គឺផ្តល់ឱកាសឲ្យជនរងគ្រោះពីសម័យខ្មែរក្រហមបានបញ្ចេញសំលេង និងទម្លាយភាពស្ងៀមស្ងាត់អំពីការឈឺចាប់របស់ខ្លួន រួចបន្តតស៊ូដោះស្រាយផ្លូវចិត្ត ជាមួយអតីតកាលរបស់ខ្លួន។ ទស្សនៈនៅក្នុងសៀវភៅនេះបានមកពីជនរងគ្រោះម្នាក់ៗ និងមិនឆ្លុះបញ្ចាំងនូវទស្សនៈរបស់អង្គការ ធីភីអូ ឡើយ។

យើងសូមថ្លែងអំណរគុណដល់អ្នកស្រី ហ្សេលី ផូលិន និង លោក អាឡាន អែម ថនថុន ចំពោះការប្តេជ្ញាអស់ពីដួងចិត្ត ក្នុងការចងក្រងសៀវភៅនេះ និងចំពោះការស្វែងយល់យ៉ាងល្អិតល្អន់អំពីជនរងគ្រោះទាំងអស់ដែលបានចែករំលែកនូវបទពិសោធន៍របស់ពួកគាត់ក្នុងដំណើរការនេះ។

វេជ្ជបណ្ឌិត ឈឹម សុធារ៉ា នាយកប្រតិបត្តិ អង្គការ ធីភីអូ

# IWITNESS:

## THE POWER OF STORYTELLING FOR SURVIVORS OF THE KHMER ROUGE

During the years of 1975-1979 Cambodia suffered one of the most brutal genocidal terrors in the history of mankind. In the name of creating a classless society Pol Pot and his Khmer Rouge army killed nearly two million people through execution, torture or being worked or starved to death. The Khmer Rouge separated families, removed intellectuals and Buddhist monks, documented meticulously the torture of thousands of individuals, and sent hundreds of thousands into forced labor in the countryside. The physical onslaught stopped in large part when Vietnam invaded in 1979; but for many, the psychological scars have yet—nearly thirty years later—to be reckoned with.

This project is about witnessing. It is also about history and about healing. In collaboration with the Transcultural Psychosocial Organization Cambodia (TPO) we set out to interview and photograph survivors of the Khmer Rouge regime, many of whom are civil parties of Cases 001 and 002 of the ECCC.
We wanted to bear witness to their personal stories and document not only what happened to people in Cambodia during the Khmer Rouge regime, but also to acknowledge the lasting psychological impacts that are still present in Cambodia today.

In listening to people, we also honor their experiences: the horrors, the injustices and cruelty they experienced, as well as their amazing resilience and strength of character. The portraits we created are further meant to capture each individual's dignity, strength and beauty. Those who worked with us were brave and articulate. They shared their time and some of their most painful, intimate experiences as a means to heal, to document history, and to seek justice. We share here just a sample of voices and images.

This project was made possible in part through a Rotary World Peace Fellowship. We hope that the results will contribute to a national search for justice and real reconciliation in Cambodia, because it is often only in recognizing and reconciling with the past that people can truly move forward.

ZÉLIE POLLON AND ALAN M. THORNTON

# សាក្សីឃើញផ្ទាល់ភ្នែក:

## អំណាចនៃការនិទានរឿង របស់ជនរងគ្រោះពីសម័យខ្មែរក្រហម

ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ កម្ពុជាបានទទួលរងភាពតក់ស្លុតមួយក្នុងចំណោមភាពតក់ស្លុតពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដ៏ព្រៃផ្សៃជាច្រើន ក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ។ ក្រោមឈ្មោះថាបង្កើតសង្គមមួយដែលគ្មានវណ្ណៈ ប៉ុលពតនិងទាហានខ្មែរក្រហមបានសម្លាប់ប្រជាជនជិត២លាននាក់ តាមវិធីយកទៅសម្លាប់ ធ្វើទារុណកម្ម ឬឲ្យធ្វើការជាទម្ងន់ ឬបង្អត់អាហារ រហូតដល់ស្លាប់។ ខ្មែរក្រហមបានបំបែកបំបាក់ក្រុមគ្រួសារ បំបាត់អ្នកចេះដឹង និងព្រះសង្ឃ បានកត់ត្រាយ៉ាងល្អិតល្អន់អំពីការធ្វើទារុណកម្មមនុស្សរាប់ពាន់នាក់ (គ្រាន់តែនៅទួលស្លែង...) ហើយបានបញ្ជូនរាប់សែនពាន់នាក់ទៀតទៅជនបទ រួចបង្ខំឲ្យធ្វើការ។ ការធ្វើបាបខាងរាងកាយបានបញ្ចប់មួយផ្នែកធំពេលវៀតណាមចូលមកនៅឆ្នាំ១៩៧៩ ប៉ុន្តែសម្រាប់ជនរងគ្រោះជាច្រើន ស្នាមរបួសផ្លូវចិត្តនៅមាននៅឡើយ បើទោះជាមានរយៈពេលជិត៣០ឆ្នាំក្រោយមកក៏ដោយ ក៏ពួកគាត់នៅតែគិត។

គំរោងនេះគិតគូរអំពីការមើលឃើញផ្ទាល់ភ្នែក។ វាក៏ជាប្រវត្តិសាស្ត្រនិងជាការព្យាបាលផងដែរ។ ដោយសហការជាមួយអង្គការ ធីភីអូកម្ពុជា យើងធ្វើកិច្ចសម្ភាសន៍ និងថតរូបជនរងគ្រោះពីសម័យខ្មែរក្រហមដែលភាគច្រើនជាដើមបណ្ដឹងរដ្ឋប្បវេណីសំណុំរឿង០០១និង០០២នៃអវតក។ យើងចង់ធ្វើជាសាក្សីនៃរឿងរ៉ាវផ្ទាល់ខ្លួនរបស់ពួកគាត់រួចកត់ត្រាមិនត្រឹមតែអ្វីដែលបានកើតឡើងចំពោះប្រជាជនកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែទទួលស្គាល់ផលប៉ះពាល់ផ្លូវចិត្តយូរអង្វែង ដែលកំពុងមាននៅកម្ពុជាបច្ចុប្បន្នផងដែរ។
ដោយការស្ដាប់ប្រជាជន យើងផ្តល់កិត្តិយសដល់បទពិសោធន៍របស់ពួកគាត់ ដែលក្នុងនោះរួមមានសេចក្តីវេទនា ភាពអយុត្តិធម៌ និងភាពព្រៃផ្សៃ ដែលពួកគាត់បានជួបប្រទះ ក៏ដូចជា ភាពធន់ទ្រាំ រួមនិងភាពមាំទាំដ៏អស្ចារ្យរបស់ពួកគាត់។ រូបថតដែលយើងបានបង្កើតនេះ មានអត្ថន័យជ្រាលជ្រៅថែមទៀត ដើម្បីបង្ហាញនូវសោភ័ណភាព ភាពខ្លាំង និងកិត្តិយសរបស់គាត់ម្នាក់ៗ។ ពួកគាត់ដែលចូលរួមជាមួយយើងគឺជាមនុស្សក្លាហានហើយប៉ិនប្រសប់។ ពួកគាត់បានចែករំលែកពេលវេលា និងបទពិសោធន៍ដ៏ឈឺចាប់បំផុតខ្លះៗរបស់គាត់ ធ្វើជាមធ្យោបាយព្យាបាលផង ទុកជាឯកសារប្រវត្តិសាស្ត្រផង និងដើម្បីស្វែងរកយុត្តធម៌ផង។ យើងចែករំលែកនៅទីនេះ គ្រាន់តែជាសម្លេង និងរូបភាពខ្លះៗតែប៉ុណ្ណោះ។

កិច្ចការនេះអាចដំណើរការទៅបានក៏ដោយសារ Rotary Peace Fellowship ។ យើងសង្ឃឹមថាលទ្ធផលនៃការងារនេះ នឹងចូលរួមចំណែកក្នុងការរកយុត្តិធម៌នៅក្នុងប្រទេស រួមទាំងការផ្សះផ្សាយ៉ាងពិតប្រាកដនៅកម្ពុជា ពីព្រោះថាជារឿយៗ មានតែការទទួលស្គាល់និងផ្សះផ្សារឿងអតីតកាលប៉ុណ្ណោះ ទើបប្រជាជនអាចវិវឌ្ឍន៍ឈានទៅមុខពិតប្រាកដបាន។

ហ្សេលី ផូលិន និង លោកអាឡាន មែខល ថនថុន

# SUM RITHY

## 57, PHNOM PENH

Rithy was twenty one years old when he was arrested and sent to prison for two years in Siem Reap. Despite torture and repeated traumatic experiences, he survived in large part because he could fix motorbikes. He first filed a complaint in 1979, only one of two people to do so. The Siem Reap prison complex where he was held has since been transformed into a luxury Sokha hotel.

“ My mother is still alive, and after the regime I had to tell her about my little brother. He was eight years old and he stole a papaya. They buried him in the earth and then slit his throat. When he tried to climb out, they slit his neck again and killed him. Because he stole a papaya.

I came to TPO on my own. I had to find a way to talk about what happened, about my experience. At the beginning I didn't think about it all. Even when I passed the prison, it didn't affect me. At the beginning I forgot even the name of the prison guard. Then, in 1990, I remembered his name. That year my family situation was so difficult that I started to remember. We were so poor, and in 1983 Pol Pot soldiers burned my house… It brought back memories of my time in prison. One of my strongest memories is the stink of dead bodies. Today if I smell fish or dead animals then I smell it again. It smelled so terrible and we couldn't escape. We couldn't walk far enough to get away from the smell. All survivors want justice, and most people just want to know the answers. I want the top leaders to tell the truth, then survivors would feel justice, even the perpetrators might feel justice. Like how many people were brought into the prison, how many were killed?

Duch knows. Even the concrete and the rats coming into the prison knew what happened. It makes me and the other survivors mad when he lies. Why lie? Once they tell the truth there will be justice for everyone. There will be justice for me. ”

# ស៊ុំ រិទ្ធី

## អាយុ ៥៧ ឆ្នាំ មកពី ភ្នំពេញ

រិទ្ធី មានអាយុ២១ឆ្នាំនៅពេលដែលគាត់ត្រូវគេចាប់ខ្លួនបញ្ជូនទៅពន្ធនាគារ ក្នុងខេត្តសៀមរាប អស់រយៈពេល២ឆ្នាំ។ បើទោះជាទទួលរងនូវទារុណកម្មផ្លូវកាយ និងផ្លូវចិត្តដ៏ធ្ងន់ធ្ងរ ក៏គាត់នៅតែអាចរស់រានមានជីវិតបាន ដោយមូលហេតុចំបងមួយគឺ គាត់ចេះជួសជុលម៉ូតូ។ គាត់បានដាក់ពាក្យបណ្តឹងជាលើកដំបូងក្នុងឆ្នាំ១៩៧៩ ដែលកាលនោះមានមនុស្សម្នាក់ឬពីរនាក់ប៉ុណ្ណោះ បានដាក់ពាក្យប្តឹង។ ពន្ធនាគារខេត្តសៀមរាបជាកន្លែងដែលគេឃុំឃាំង លោកស៊ុំ រិទ្ធី ហើយក្រោយមកបានអភិវឌ្ឍទៅជា"សណ្ឋាគារសុខា"ដ៏ប្រណិត។

“ ម្តាយរបស់ខ្ញុំនៅមានជីវិតនៅឡើយ ហើយបន្ទាប់ពីរបបខ្មែរក្រហមបានបញ្ចប់ ខ្ញុំបានប្រាប់គាត់ពីរឿងប្អូនប្រុសរបស់ខ្ញុំ។ ពេលនោះប្អូនខ្ញុំអាយុ៨ឆ្នាំ វាបានលួចល្ហុងមួយផ្លែ ។ពួកគេបានកប់វានៅក្នុងរណ្តៅ ហើយបន្ទាប់មកអារកវា។ នៅពេលវាព្យាយាមឡើងពីរណ្តៅ ពួកគេបានអារកវាម្តងទៀត ដើម្បីសម្លាប់វាតែម្តង។ មូលហេតុគឺដោយសារតែវាលួចផ្លែល្ហុងមួយផ្លែ។

ខ្ញុំបានមកកាន់អង្គការ TPO ដោយខ្លួនឯង។ ខ្ញុំត្រូវតែរកវិធីនិយាយនូវអ្វីដែលបានកើតឡើង ពោលគឺអ្វីដែលខ្ញុំធ្លាប់ឆ្លងកាត់។ កាលពីដំបូង ខ្ញុំមិនដែលគិតពីរឿងនេះទេ ហើយក៏អត់ចាំឈ្មោះអ្នកយាមគុកនោះដែរ។ ទោះបីជាខ្ញុំធ្វើដំណើរឆ្លងកាត់គុកនោះ វាអត់ធ្វើឲ្យខ្ញុំមានអារម្មណ៍អ្វីឡើយ។ ក្រោយមក ខ្ញុំនឹកឃើញឈ្មោះអ្នកយាមនោះក្នុងឆ្នាំ១៩៩០។ នៅឆ្នាំនោះ ស្ថានភាពគ្រួសាររបស់ខ្ញុំមានការលំបាកយ៉ាងខ្លាំង ទើបបានជាខ្ញុំចាប់ផ្តើមនឹកឃើញ។ កាលពីឆ្នាំ ១៩៨៣ ទាហានប៉ុលពតបានដុតផ្ទះរបស់ខ្ញុំ ដែលធ្វើឲ្យគ្រួសារខ្ញុំធ្លាក់ខ្លួនក្រយ៉ាងខ្លាំង... ហើយវាធ្វើឲ្យខ្ញុំនឹកឃើញឡើងវិញពីពេលដែលខ្ញុំនៅក្នុងគុក។ ការចងចាំដិតជាប់ខ្លាំងបំផុតក្នុងអារម្មណ៍របស់ខ្ញុំ គឺក្លិនអាសោចន៍នៃសាកសពទាំងនោះ។ បច្ចុប្បន្ននេះ ពេលដែលខ្ញុំធុំក្លិនត្រី ឬខ្មោចសត្វពេលនោះ ខ្ញុំនឹកឃើញដល់ក្លិននោះភ្លាម។ វាស្អុយខ្លាំងណាស់ ហើយពួកយើងមិនអាចគេចផុតពីក្លិននោះបានឡើយ ។ ពួកយើងមិនអាចដើរចេញឲ្យឆ្ងាយផុតពីក្លិននោះបានឡើយ ។

អ្នកនៅរស់គ្រប់រូបចង់បានយុត្តិធម៌ ហើយមនុស្សភាគច្រើនគ្រាន់តែចង់ដឹងនូវចំលើយពិតប៉ុណ្ណោះ។ ខ្ញុំចង់ឲ្យមេដឹកនាំខាងលើៗប្រាប់ចម្លើយពិត ដើម្បីឲ្យអ្នករស់រានមានជីវិតទាំងអស់មានអារម្មណ៍ថា ទទួលបានយុត្តិធម៌ ហើយសូម្បីតែឧក្រិដ្ឋជនខ្លួនឯងក៏ប្រហែលជាមានអារម្មណ៍ថាទទួលបានយុត្តិធម៌ដែរ។ ដូចជាថា តើមានប្រជាជនប៉ុន្មាននាក់ត្រូវបានគេចាប់ដាក់គុក ហើយប៉ុន្មាននាក់ត្រូវបានគេយកទៅសម្លាប់?

ឌុច ដឹងអ្វីៗទាំងអស់ សូម្បីតែជញ្ជាំងឬកណ្តុរនៅក្នុងគុក ក៏ដឹងថាមានអ្វីខ្លះកើតឡើងដែរ។ វាធ្វើឲ្យខ្ញុំ និងអ្នករួចពីស្លាប់ដទៃទៀតខឹងយ៉ាងខ្លាំង នៅពេលដែល ឌុច និយាយកុហក។ ហេតុអ្វីចាំបាច់កុហក? នៅពេលពួកគេប្រាប់ពីការពិត ពេលនោះនឹងមានយុត្តិធម៌សំរាប់មនុស្សគ្រប់រូប ហើយក៏នឹងមានយុត្តិធម៌សំរាប់រូបខ្ញុំដែរ។ ”



## PRAK SINAN

### 55, KAMPOT

Sinan was imprisoned in Kampot province for three months, and forced to marry a man she did not know and did not love. Her most important claim against the Khmer Rouge regime leaders is that because of the forced hard labor she has never been able to have children.

“ We went into the forest to collect vegetables. I lifted my head and saw a mango on a tree. I really wanted the mango so I climbed the tree. From up high I saw Khmer Rouge soldiers bringing about thirty victims, mostly women and children. I saw the soldiers kill all the people. They stripped them first, took off all their clothes. To kill the children they would take them by the leg and throw them against a tree. For the adults they used a big stick and hit them on the back of the head. They had a big hole in the ground and they put the bodies in the hole after they hit them… I felt my spirit leave my body and I lost consciousness… After that, when someone would disappear I would imagine that that's what was happening to them.

As for reparations, anything that can help people psychologically would be helpful. Most people here, especially those over 30 years of age, suffer psychologically. They work hard to get over it. I don't know if some of them would be brave enough to tell their story like me. But they call me. And they tell me.

I always thought since the regime that no leader would let this happen to the people… During the regime, the government killed people but now they grab their land, and Cambodian people depend on the land to make a living. Now they kill the people by taking their land. ”

## ប្រាក់ ស៊ីណាន

### អាយុ ៥៥ ឆ្នាំ មកពី កំពត

ស៊ីណាន ជាប់គុកអស់រយៈពេលបីខែនៅខេត្តកំពត ហើយត្រូវគេបង្ខំឲ្យរៀបការជាមួយប្រុសម្នាក់ដែលគាត់មិនធ្លាប់ស្គាល់ និងមិនធ្លាប់ស្រលាញ់។ បណ្តឹងសំខាន់បំផុតរបស់គាត់ប្រឆាំងនឹងមេដឹកនាំខ្មែរក្រហមគឺ ដោយសារតែការបង្ខំឲ្យធ្វើការយ៉ាងធ្ងន់ធ្ងរហួតដល់គាត់មិនអាចមានកូនបាន។

“ ពួកយើងចូលព្រៃបេះបន្លែ។ ខ្ញុំងើយមើលទៅលើ ឃើញផ្លែស្វាយលើដើម។ ខ្ញុំចង់ហូបស្វាយ ហើយខ្ញុំបានឡើងបេះស្វាយ។ ពីលើដើមស្វាយ ខ្ញុំឃើញទាហានខ្មែរក្រហមបណ្តើរជនរងគ្រោះប្រហែល៣០នាក់ ដែលភាគច្រើនជាស្ត្រី និងកូនក្មេង។ ខ្ញុំឃើញពួកទាហានទាំងនោះសម្លាប់ពួកគេទាំងអស់។ ដំបូងឡើយ ពួកគេដោះខោអាវជនរងគ្រោះចេញអស់។ ចំពោះក្មេងៗ ពួកគេសម្លាប់ដោយចាប់ជើងបោកផ្ទប់នឹងដើមឈើ។រីឯមនុស្សធំត្រូវគេវាយក្បាលពីក្រោយជាមួយនឹងដំបងដ៏ធំមួយ។ សាកសពទាំងនោះត្រូវគេទម្លាក់ចូលទៅក្នុងរណ្តៅ ដែលគេបានជីកទុកជាមុនស្រេច។ ខ្ញុំមានអារម្មណ៍ថាព្រលឹងខ្ញុំហោះចេញពីរាងកាយ ហើយបន្ទាប់មក ខ្ញុំបាត់ស្មារតី។ ចាប់តាំងពីនោះមក នៅពេលដែលមាននរណាម្នាក់បាត់ខ្លួន ខ្ញុំតែងតែស្រមៃឃើញរាល់អ្វីទាំងនោះ នឹងកើតមានចំពោះពួកគេ។

ចំពោះសំណងអ្វីក៏ដោយ ឲ្យតែអាចជួយប្រជាជនផ្នែកសតិអារម្មណ៍ឬផ្លូវចិត្តបាន គឺសុទ្ធតែមានប្រយោជន៍។ ប្រជាជនកម្ពុជាភាគច្រើន ជាពិសេសអ្នកដែលមានវ័យលើសពី៣០ឆ្នាំ សុទ្ធតែទទួលរងការប៉ះពាល់ផ្នែកផ្លូវចិត្ត។ ពួកគេព្យាយាមបំភ្លេចរឿងទាំងអស់នោះ។ ខ្ញុំមិនដឹងថា តើមានពួកគេប៉ុន្មាននាក់ទេ ដែលមានភាពក្លាហានក្នុងការនិយាយរឿងរ៉ាវរបស់ពួកគេដូចជាខ្ញុំ។ ប៉ុន្តែ ពួកគេបានទូរស័ព្ទមកខ្ញុំ ហើយនិយាយរឿងរបស់គេប្រាប់ខ្ញុំ។

ខ្ញុំតែងគិតថា គ្មានមេដឹកនាំណានឹងបណ្តោយឲ្យរឿងទាំងនេះកើតឡើងចំពោះប្រជាជនខ្លួនឡើយ...។ ក្នុងសម័យខ្មែរក្រហម រដ្ឋាភិបាលសម្លាប់ប្រជាជន ប៉ុន្តែបច្ចុប្បន្ននេះ ពួកគេដណ្តើមដីប្រជាជន ហើយដែលប្រជាជនខ្មែរពឹងផ្អែកលើដីទាំងអស់ហ្នឹង ដើម្បីប្រកបរបរចិញ្ចឹមជីវិត។ ឥឡូវពួកគេសម្លាប់ប្រជាជនដោយដកយកដីពីពួកគាត់។ ”



## SAM SOKHUN

### 60, KAMPOT

In early 1971 Pol Pot chose two medics to work on the front line, including Sokhun. He was assigned to bandage the injured and write letters to the family members of dead soldiers. "That was a very difficult job," he said. After dressing the wounds, soldiers would be sent to a small hospital in the forest.

" One day we did a medical experiment on a twenty five-year-old man. He was one of the 'new people'. We injected adrenaline into his heart to see the effects. We didn't mean to kill him, but we put too much and he started shaking and died. They tried to bring him back, but he overdosed.

Another time we arrested a woman and brought her in for experimentation. We injected her with phenergan and morphine to make her unconscious. She didn't become unconscious so someone hit her on the back of the neck. Then we cut the body to check the breast, the abdomen, the buttocks, the whole body. We only did this to 'new people' to show to the medic students.

After one battle, Pol Pot accused one of the soldiers of being a spy. I saw my assistant sharpening a knife and I asked what he was doing. He said he was preparing to cook a dog! Then they brought in the soldier and shot him. There was a grave nearby already dug. My assistant cut his body open and took out his gall bladder. He dried it and then put it in wine. Then we were asked to come drink it. It was supposed to be a kind of medicine but I don't know for what. The leader drank the wine and his eyes became yellow and reddish. He looked aggressive and mean. I was afraid there might be a virus in there so I drank just a little bit.

I've never told anyone my background before, but I feel happy to be telling the truth. I know a lot, and when I die I don't want it to end there. "

## សម សុខហ៊ុន

### អាយុ ៦០ ឆ្នាំ មកពី កំពត

នៅដើមឆ្នាំ១៩៧១ ប៉ុលពតបានជ្រើសរើសគ្រូពេទ្យ២នាក់ឲ្យបំរើការជាទាហានជួរមុខ ក្នុងនោះមាន សុខហ៊ុន ផងដែរ។ គេឲ្យគាត់ទទួលបន្ទុករុំរបួសឲ្យកងទ័ព និងសរសេរសំបុត្រផ្ញើឲ្យគ្រួសារទាហានពលី។ គាត់និយាយថា "នោះគឺជាការងារដ៏ពិបាក"។ បន្ទាប់ពីសំអាតរបួសហើយ គេបញ្ជូនទាហានទាំងនោះទៅកាន់មន្ទីរពេទ្យតូចមួយនៅក្នុងព្រៃ។

" ថ្ងៃមួយ យើងបានធ្វើពិសោធន៍វេជ្ជសាស្ត្រមួយ លើបុរសម្នាក់អាយុ២៥ឆ្នាំ ដែលជាប្រជាជនថ្មី។ យើងបានចាក់ថ្នាំ "អាដ្រេណាលីន" ទៅក្នុងសាច់បេះដូងគាត់ ដើម្បីពិនិត្យមើលឥទ្ធិពលថ្នាំ។ យើងមិនមានបំណងសម្លាប់គាត់ទេ តែយើងបានចាក់ថ្នាំជ្រុល ទើបគាត់ចាប់ផ្តើមញ័រហើយក្រោយមកក៏ស្លាប់។ ពួកគេបានព្យាយាមជួយសង្គ្រោះគាត់ដែរ តែគាត់ទទួលឥទ្ធិពលពីថ្នាំដែលប្រើហួសកំរិត។

មានម្តងទៀតនោះ យើងបានចាប់នារីម្នាក់យកមកពិសោធន៍។ យើងបានចាក់ថ្នាំ"ហ្វេនែរហ្គង់" និង"ម័រហ្វីន" ដើម្បីធ្វើឲ្យគាត់សន្លប់។ តែគាត់អត់សន្លប់ទេ ដូចនេះគេក៏បានវាយកញ្ចឹងករបស់គាត់ពីក្រោយ។ បន្ទាប់មកយើងធ្វើការវះកាត់លើរាងកាយរបស់គាត់ ដើម្បីត្រួតពិនិត្យដើមទ្រូង ពោះ ត្រគាក ព្រមទាំង សារពាង្គកាយទាំងមូល។ យើងធ្វើបែបនេះ ចំពោះតែ " ប្រជាជនថ្មី " ប៉ុណ្ណោះ ដើម្បីបង្ហាត់បង្ហាញដល់សិស្សពេទ្យ។

មានពេលមួយនោះ ក្រោយពីការប្រយុទ្ធចប់ ទាហានម្នាក់ត្រូវប៉ុលពតចោទថាជាអ្នកស៊ើបការណ៍។ ខ្ញុំបានឃើញជំនួយការរបស់ខ្ញុំសំលៀងកាំបិត ហើយខ្ញុំក៏បានសួរថា តើគាត់កំពុងធ្វើអ្វី? គាត់ប្រាប់ខ្ញុំថាគាត់កំពុងរៀបចំធ្វើម្ហូបសាច់ឆ្កែ! ហើយរំពេចនោះ ពួកគេក៏ចាប់ទាហានម្នាក់នោះចូលមក រួចក៏បាញ់គាត់ចោល។ មានផ្នូរមួយគេជីកទុកជាស្រេចនៅក្បែរនោះ។ ជំនួយការរបស់ខ្ញុំបានវះសាកសពទាហាននោះ ហើយយកប្រម៉ាត់ចេញ។ គាត់យកប្រម៉ាត់ទៅឆ្អើរ ដើម្បីត្រាំស្រា។ បន្ទាប់មក ពួកគេបានហៅយើងទៅផឹកស្រានោះ។ ពួកគេគិតថា វាជាថ្នាំ តែខ្ញុំអត់ដឹងថា វាជាថ្នាំអ្វីនោះទេ។ មេរបស់ខ្ញុំផឹកមុន ហើយភ្នែករបស់គាត់បានប្រែជាពណ៌លឿង និងក្រហម។ គាត់មើលទៅដូចជាកាចសាហាវ និងកំណាច។ ខ្ញុំខ្លាចថា មានមេរោគឆ្លងនៅក្នុងនោះ ដូច្នេះហើយ ខ្ញុំផឹកតែបន្តិចប៉ុណ្ណោះ។

កន្លងមក ខ្ញុំមិនដែលប្រាប់អ្នកណាពីប្រវត្តិរបស់ខ្ញុំឡើយ ប៉ុន្តែឥឡូវនេះខ្ញុំមានអារម្មណ៍រីករាយ ដែលបាននិយាយការពិត ព្រោះថាខ្ញុំបានដឹងរឿងជាច្រើន ហើយពេលស្លាប់ទៅខ្ញុំមិនចង់ឲ្យរឿងទាំងអស់នោះបាត់ទៅតាមខ្ញុំឡើយ។ "





“I will never forget what the Khmer Rouge did,
if possible for one hundred lives.”

**SULAIMAN, KAMPOT**

ខ្ញុំនឹងនៅតែចងចាំខ្មែរក្រហមជានិច្ច ហើយបើអាចទៅរួច
ខ្ញុំចង់ចាំអោយបាន១០០ជាតិ។

**សូឡាយម៉ាន់ មកពី កំពត**